**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...០៤...សរណន

**សារាចរណែនាំ**

**ស្តីពី**

**ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១០**

## I. សេចក្តីផ្តើម

១- មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានបែងចែកកិច្ចដំណើរការនៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ជា ៣ ដំណាក់កាលគឺ (១) *ដំណាក់កាលទី១:* ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាពីខែមីនា ដល់ខែឧសភា (២) *ដំណាក់កាលទី ២:* ការរៀបចំកញ្ចប់ថវិកា ពីខែមិថុនា ដល់ខែកញ្ញា និង*ដំណាក់កាលទី ៣:* ការអនុម័តថវិកាពីខែ តុលា ដល់ខែធ្នូ ។ ដើម្បីធានាការអនុវត្តច្បាប់នេះ និងដើម្បីបង្កើនការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ រាជរដ្ឋាភិបាលត្រូវចេញសារាចរណែនាំពីរគឺ ***សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា*** នៅដើមខែមេសា សម្រាប់ដំណាក់កាលទី ១ និង ***សារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងប្រចាំឆ្នាំ*** នៅដើមខែមិថុនា សម្រាប់ដំណាក់កាលទី ២ ។ ដូច្នេះ សារាចរនេះគឺជាមគ្គុទ្ទេសក៍ សម្រាប់ណែនាំ និងធ្វើជាជំនួយដល់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០១០-២០១២ ដល់គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញគ្រប់រាជធានី ខេត្តទាំងអស់ ។

២- ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកា ជាពិសេស ដើម្បីបង្កើនការវិភាជន៍ថវិកាអោយចំទិសដៅ និងបំរើអោយសកម្មភាពអាទិភាពជាក់ស្តែងរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ក្នុងគោលដៅសំរេចអោយបាន នូវគោលនយោបាយយុទ្ធសាស្ត្ររបស់ក្រសួង-ស្ថាប័ននីមួយៗ ក៏ដូចជាគោលនយោបាយយុទ្ធសាស្ត្រជាអាទិភាពរបស់វិស័យនីមួយៗ សំរាប់រួមចំណែក សំរេចអោយបាននូវគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ជាពិសេស **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** តម្រូវអោយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី ខេត្តនីមួយៗ រៀបចំ និង ធ្វើបច្ចុប្បន្នភាព ***ផែនការយុទ្ធសាស្ត្រថវិកា*** ជារៀងរាល់ឆ្នាំ ។ ផែនការយុទ្ធសាស្ត្រថវិកានេះ គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ (១) ផ្សារភ្ជាប់គោលនយោបាយទៅនឹងថវិកា (២) បង្កើនសុក្រឹតភាពក្នុងការគណនាតម្រូវការថវិកា (៣)ជាមូលដ្ឋានសម្រាប់ពន្យល់ និងធ្វើអំណះអំណាងលើតម្រូវការថវិកា (៤) ធានានិរន្តរភាពនៃកម្មវិធី

និងយុទ្ធសាស្ត្រ អាទិភាព និងពិសេស (៤) គឺជាមូលដ្ឋានសម្រាប់វាយតំលៃលើអាទិភាពក្នុងការកំណត់កញ្ចប់ និង វិភាជន៍ថវិកា ។

៣- ផែនការយុទ្ធសាស្ត្រថវិកានេះ បាន និងកំពុងក្លាយជាឧបករណ៍ និងយន្តការដ៏សំខាន់សម្រាប់បង្កើនប្រសិទ្ធភាពនៃការវិភាជន៍ និងការគ្រប់គ្រងថវិកា ជាពិសេស សម្រាប់ធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន ទាំងថវិកាជាតិ និងថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ ឱ្យទៅជាថវិកាមួយឯកភាព និងគ្រប់ជ្រុងជ្រោយ ។ ដើម្បីអោយការរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះ អាចប្រព្រឹត្តទៅដោយរលូន និងគ្រប់ជ្រុងជ្រោយ ជាពិសេស ដោយផែនការយុទ្ធសាស្ត្រថវិកានេះ តម្រូវអោយផ្សារភ្ជាប់ទៅនឹងគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងបញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធន ព្រមទាំងថវិកាជាតិ និងថវិកាដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ផងនោះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវប្រើប្រាស់ក្រុមការងារថវិការបស់ក្រសួង-ស្ថាប័ន ដែលមានសមាសភាពមកពីនាយកដ្ឋានហិរញ្ញវត្ថុ ឬ/និងគណនេយ្យ នាយកដ្ឋានផែនការ និងអង្គភាពគ្រប់គ្រងគំរោង ។ ក្រុមការងារនេះ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយផ្អែកលើគោលនយោបាយអាទិភាពរបស់ក្រសួង-ស្ថាប័ន និងវិស័យ ដើម្បីដាក់ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពិនិត្យសំរេច និង ចុះហត្ថលេខា ។ គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាដែលបានរៀបចំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) អោយបាន ***ត្រឹមថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៩*** ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យ និង អាចអញ្ជើញតំណាងក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត មកពិគ្រោះ និងសាកសួរព័ត៌មានបន្ថែមក្នុងករណីចាំបាច់ ។ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ដែលមិនបានផ្តល់ផែនការយុទ្ធសាស្ត្រថវិកាតាមពេលវេលាកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិវិភាជន៍កញ្ចប់ថវិកាដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកា និងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ ។

## II. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ

### *ក. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច*

៤- សេដ្ឋកិច្ចកម្ពុជាកំពុងតែបន្តវិវត្តផ្លាស់ប្តូររចនាសម្ព័ន្ធ ដើម្បីឈានទៅរកដំណាក់កាលនៃការអភិវឌ្ឍន៍មួយខ្ពស់ជាងមុន ដែលឆ្លុះបញ្ចាំងតាមរយៈ ការកើនឡើងជាលំដាប់នៃសមាមាត្រវិស័យឧស្សាហកម្ម និងសេវាកម្ម ធៀបនឹងកសិកម្ម នៅក្នុងរចនាសម្ព័ន្ធនៃផលិតផលក្នុងស្រុកសរុប (ផសស) ។ ជាក់ស្តែង ទោះជាផលិតភាពនៃវិស័យកសិកម្មបាន និង បន្តកើនឡើង តែកំណើននៃវិស័យឧស្សាហកម្ម និងសេវាកម្ម បានកើនឡើងលឿនជាងពីមួយឆ្នាំទៅមួយឆ្នាំ ដែលធ្វើអោយការរួមចំណែកនៃវិស័យកសិកម្មថយចុះនៅឆ្នាំ ២០០៨ មកនៅត្រឹមប្រមាណ ២៧% ហើយវិស័យឧស្សាហកម្មឡើងដល់ប្រមាណ ២៨% និងវិស័យសេវាកម្មឡើងដល់ ៤០% ។ ទោះជាយ៉ាងណាក៏ដោយ វិស័យកសិកម្មនៅតែជាមូលដ្ឋានសំខាន់ និងមានសក្តានុពលខ្ពស់ក្នុងការជំរុញ និង ពង្រីកកំណើនសេដ្ឋកិច្ចកម្ពុជា ជាពិសេស នៅក្នុងបរិការណ៍ដែលវិស័យឧស្សាហកម្ម និងសេវាកម្ម បាន និង កំពុងរងឥទ្ធិពលនៃវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងនៃឱនភាព

សេដ្ឋកិច្ចពិភពលោក ។ ប្រការនេះ កាន់តែបញ្ជាក់អោយឃើញថា ការបង្កើនទិន្នផល និងផលិតភាពកសិកម្ម ការធ្វើពិពិធភាវូបនីយកម្មមូលដ្ឋាននៃកំណើនវិស័យកសិកម្ម និង ការជំរុញការអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម ព្រមទាំងសហគ្រាសធុនតូច និង មធ្យម រួមទាំងការកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ នៅតែជាយុទ្ធសាស្ត្រដ៏សំខាន់ និងចាំបាច់ ដើម្បីបង្កើនតម្លៃបន្ថែមលើផលិតផលកសិកម្ម និង ស្រូបយកពលកម្ម ដែលចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេស ពលកម្មដែលត្រូវផ្ទេរចេញពីវិស័យកសិកម្ម និងដើម្បីពង្រីកមូលដ្ឋានកំណើន រក្សាចីរភាព និងសមធម៌នៃកំណើនសេដ្ឋកិច្ច ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ របស់ប្រជាជនស្របតាមគោលនយោបាយ **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២** ក៏ដូចជា **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ។

៥- ឆ្នាំ ២០០៨ កន្លងទៅនេះ តាមការគណនាបឋមរបស់វិទ្យាស្ថានជាតិស្ថិតិ កំណើនសេដ្ឋកិច្ចអាចនឹងសម្រេចបានប្រមាណ ៦,៨% ទោះជាត្រូវរងនូវឥទ្ធិពលអវិជ្ជមានពីខាងក្រៅតាំងពីចុងឆ្នាំ ២០០៧ រហូតមកដូចជាកត្តាអតិផរណាខ្ពស់ ការចាប់ធ្លាក់ចុះនូវការនាំចេញសំលៀកបំពាក់ និងចំនួនភ្ញៀវទេសចរ ព្រមទាំងការធ្លាក់ចុះនៃទីផ្សារអចលនទ្រព្យ ដោយសារវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងឱនភាពសេដ្ឋកិច្ចពិភពលោកដែលចាប់ផ្តើមពីសហរដ្ឋអាមេរិកក៏ដោយ ។ លទ្ធផលនេះ បានមកដោយសារវិស័យកសិកម្មបានកើនឡើងប្រមាណ ៥,៤% លើកំណើន ៥% នៅក្នុងឆ្នាំ ២០០៧ វិស័យឧស្សាហកម្មបានកើនឡើងប្រមាណ ៦,៥% លើកំណើន ៨,៤% នៅក្នុងឆ្នាំ ២០០៧ (ដែលក្នុងនោះ ផលិតផលវាយនភ័ណ្ឌបានកើនឡើងត្រឹមប្រមាណ ៦,៥% លើកំនើន ១០% នៅក្នុងឆ្នាំ ២០០៧ ហើយផលិតផលសំណង់បានកើនឡើងត្រឹមប្រមាណ ៦,៥% លើកំនើន ៦,៧% នៅក្នុងឆ្នាំ ២០០៧) ហើយវិស័យសេវាកម្មបានកើនឡើងប្រមាណ ៨% លើកំណើន ១០% នៅក្នុងឆ្នាំ ២០០៧ (ដែលក្នុងនោះ អាជីវកម្មទេសចរណ៍ បានកើនឡើងប្រមាណ ៨% លើកំណើន ១០% នៅក្នុងឆ្នាំ ២០០៧) ។

៦- តាមការព្យាករណ៍ដោយមានលក្ខណៈប្រុងប្រយ័ត្ន កំណើនសេដ្ឋកិច្ចនៅឆ្នាំ ២០០៩ នេះអាចនឹងសម្រេចបានត្រឹមប្រមាណពី ១% ទៅ ២% ធៀបទៅនឹងការព្យាករណ៍ ៦,៥% នៅក្នុងការរៀបចំច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។ ទោះជាត្រូវទទួលឥទ្ធិពលពីខាងក្រៅ ដូចជាការធ្លាក់ចុះនៃសេដ្ឋកិច្ចអាមេរិក និងការប្រឈមនឹងការប្រកួតប្រជែងលើទីផ្សារវាយនភ័ណ្ឌ ពីប្រទេសវៀតណាម និងចិនក៏ដោយ ក៏កំណើននៃតម្រូវការក្នុងស្រុក និងលំហូរចូលនៃមូលធនពីក្រៅប្រទេសនឹងនៅតែបន្តកើនឡើងគ្រប់គ្រាន់សម្រាប់រក្សាកំណើនមិនអោយធ្លាក់ចុះក្រោមសូន្យដែរ ។ ជាពិសេស វិស័យកសិកម្មនឹងនៅតែកើនឡើងប្រមាណ ៤,៥% វិស័យឧស្សាហកម្មនឹងធ្លាក់ចុះប្រមាណពី ២% ទៅ ៣% ពិសេសដោយសារការធ្លាក់ចុះនៃផលិតផលវាយនភ័ណ្ឌ និងផលិតផលសំណង់ដែលអាចធ្លាក់ដល់ប្រមាណពី ៥% ទៅ ១០% និងវិស័យសេវាកម្មនឹងអាចកើនឡើងត្រឹមប្រមាណ ១% ដោយសារអាជីវកម្មទេសចរណ៍អាចនឹងធ្លាក់ចុះប្រមាណ ៥% ។

៧- អតិផរណានៅចុងឆ្នាំ ២០០៨ បានកើនឡើងរហូតដល់ ១២,៥% (តាមឆ្នាំគោល ២០០៦) ដោយសារកត្តាឥទ្ធិពលពីខាងក្រៅនិងកត្តាកំណើនតម្រូវការក្នុងស្រុក ក៏បានរួមចំណែកក្នុងការធ្វើអោយថ្លៃទំនិញមួយចំនួនឡើងថ្លៃដែរ ជាពិសេស ម្ហូបអាហារ និងសំភារៈប្រើប្រាស់ ដោយសារចំណូលរបស់ប្រជាជនបានកើនឡើង និងកំណើនទេសចរណ៍ ។ តាមការព្យាករណ៍ អតិផរណា ជាមធ្យមនៅក្នុងឆ្នាំ ២០០៩ នឹងធ្លាក់មកនៅត្រឹមរង្វង់ប្រមាណ ៤% (តាមឆ្នាំគោល២០០៦) និងនៅឆ្នាំ ២០១០ ខាងមុខអាចនឹងស្ថិតនៅក្នុងរង្វង់ប្រមាណ ៥% ដោយសារសេដ្ឋកិច្ចពិភពលោកបានក្រឡាប់ចាក់ ១៨០ អង្សារ គឺពីអតិផរណាខ្ពស់ ថ្លៃប្រេងឥន្ធនៈខ្ពស់ និងថ្លៃស្បៀងអាហារខ្ពស់ នៅពាក់កណ្តាលឆ្នាំ ២០០៨ មករកបដិផរណា គឺការធ្លាក់ចុះនៃថ្លៃស្បៀងអាហារ និងថ្លៃប្រេងឥន្ធនៈ និងដោយសារកត្តាក្នុងស្រុកដែលរងឥទ្ធិពលពីវិបត្តិទីផ្សារហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោក ដូចជា ការធ្លាក់ចុះនូវចំណូលរបស់ប្រជាជន និងចំនួនភ្ញៀវទេសចរ ព្រមទាំងការធ្លាក់ចុះនៃទីផ្សារអចលនទ្រព្យ ។

៨- ជារួមតាមការវាយតម្លៃ និងព្យាករណ៍របស់សហគមន៍អន្តរជាតិ ទោះជាឆ្នាំ ២០០៩ នេះ សេដ្ឋកិច្ចពិភពលោកពោរពេញដោយភាពទុទ្ទិដ្ឋិនិយមយ៉ាងណាក៏ដោយ ក៏ប្រទេសភាគច្រើនសង្ឃឹមថា សេដ្ឋកិច្ចពិភពលោកនឹងងើបឡើងវិញនៅក្នុងឆ្នាំ ២០១០ ខាងមុខនេះ ជាពិសេស បណ្តាប្រទេសនៅអាស៊ី ។ ការវាយតម្លៃ និងសេចក្តីសង្ឃឹមនេះ គឺដោយផ្អែកលើកិច្ចសហការរវាងបណ្តាប្រទេសនៅគ្រប់តំបន់ ដើម្បីជំរុញគោលនយោបាយពង្រីកចំណាយលើវិស័យសាធារណៈ ពិសេសវិស័យមានផលិតភាពខ្ពស់ និងហេដ្ឋារចនាសម្ព័ន្ធដែលជំរុញកំណើនសេដ្ឋកិច្ច និងចំណាយលើការការពារសុវត្ថិភាពសង្គម ព្រមទាំងការជួយស្រោចស្រង់វិស័យឯកជន ។ ដោយឈរលើមូលដ្ឋានខាងលើនេះ កំណើនសេដ្ឋកិច្ចត្រូវបានព្យាករណ៍សំរាប់ការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ ២០១០ គឺស្ថិតក្នុងរង្វង់ ៣% ។ ទោះជាយ៉ាងណាក៏ដោយ ស្ថិតក្នុងបរិការណ៍ប្រកបដោយភាពមិនច្បាស់លាស់ខ្ពស់បែបនេះ រាជរដ្ឋាភិបាល នឹងបន្តពង្រឹងការតាមដាន និង គ្រប់គ្រងសភាពការណ៍យ៉ាងម៉ត់ចត់ និងជាប្រចាំ ព្រមទាំងបន្តជំរុញការអនុវត្ត ប្រកបដោយភាពទន់ភ្លន់ និងដាក់ចេញនូវវិធានការថ្មីៗ ទៀតទៅតាមការវិវត្តនៃស្ថានភាពជាក់ស្តែង ។ រាជរដ្ឋាភិបាលនៅតែប្រកាន់មហិច្ឆិតាខ្ពស់ក្នុងការសំរេចឱ្យបាននូវគោលដៅកំណើនសេដ្ឋកិច្ចប្រមាណ ៧% និងកាត់បន្ថយភាពក្រីក្រឱ្យបានជាង ១% ក្នុងមួយឆ្នាំៗ ស្របតាមគោលដៅនយោបាយនៃ **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២** ។

## *ខ. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ*

៩- ទោះជាឆ្នាំ ២០០៩ នេះ កំណើនសេដ្ឋកិច្ចអាចនឹងសម្រេចបាន (១-២%) ទាបជាងគោលដៅ ៦,៥% ពេលរៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ក៏ដោយ ក៏យើងសង្ឃឹមថានឹងមិនមានឥទ្ធិពលធ្ងន់ធ្ងរមកលើស្ថានភាពហិរញ្ញវត្ថុសាធារណៈដែរ ពិសេស លើការអនុវត្តថវិកា ។ ការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពត្រឹមត្រូវ និងប្រុងប្រយ័ត្នខ្ពស់ គួបផ្សំជាមួយនឹងការជំរុញការកែលម្អ និងការពង្រឹងការប្រមូល និងគ្រប់គ្រងចំណូល និងការកែលម្អ និងពង្រឹងការអនុវត្ត និង ការគ្រប់គ្រងចំណាយ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំង

ការធ្វើអាទិភាពចំណាយឡើងវិញសមស្រប នោះនឹងអាចធ្វើអោយការអនុវត្តថវិកាឆ្នាំ ២០០៩ សម្រេចបាន តាមគោលដៅនៃច្បាប់ហិរញ្ញវត្ថុ ។ តាមការព្យាករណ៍ចំណូល សរុបនឹងអាចកើនឡើងប្រមាណ ០,២% ធៀបនឹងការអនុវត្តក្នុងឆ្នាំ ២០០៨ គឺចំណូលក្នុងស្រុកសរុបនឹងសម្រេចបាន ១១,៩៨% នៃផសស ដែលក្នុងនោះ ចំណូលសារពើពន្ធនឹងសម្រេចបាន ១០,០៥% នៃផសស (ក្នុងនោះ ចំណូលគយ និងរដ្ឋាករស្មើនឹង ៥,៣០% និងចំណូលពន្ធដារស្មើនឹង ៣,៧៥%) ចំណូលមិនមែនសារពើពន្ធ នឹងសម្រេចបាន ១,៨៣% នៃផសស ។ ចំណាយសរុបអាចនឹងកើនដល់ ១៧,៧៨% នៃផសស គឺកើនឡើងប្រមាណ ៣៨,៥% ធៀបនឹងការអនុវត្តឆ្នាំ ២០០៨ ដែលក្នុងនោះ ចំណាយចរន្តនឹងកើនដល់ប្រមាណ ១០,៦៩% នៃផសស គឺកើនឡើង ៤៤,២% ធៀបនឹងឆ្នាំ ២០០៨ និងចំណាយមូលធនអាចនឹងកើនដល់ប្រមាណ ៧,០៩% នៃផសស គឺកើនឡើងប្រមាណ ២២,១% ធៀបនឹងការអនុវត្តក្នុងឆ្នាំ២០០៨ ។ ការអនុវត្តចំណូល និងចំណាយនេះ អាចនឹងធ្វើអោយមានអតិរេកចរន្តប្រមាណ ១,២% នៃផសស និងឱនភាពថវិកាសរុបប្រមាណ ៥,៨% នៃផសស ។

១០- ដោយឈរលើមូលដ្ឋាននៃ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** របស់រាជរដ្ឋាភិបាល គួបផ្សំនឹងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ថវិកាឆ្នាំ ២០១០ មានគោលដៅសំខាន់ៗដូចតទៅ :

- ការជំរុញការអនុវត្ត **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** ***ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព*** និងធានាការបន្តអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** សំដៅសម្រេចគោលដៅនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។
- ធានាការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល ៣ ឆ្នាំ ២០១០-២០១២ ។
- ធានាការអនុវត្តគោលនយោបាយអាទិភាពតាមវិស័យ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ដូចជា:
  - ការបន្តផ្តល់អាទិភាពដល់ការបង្កើន និងលើកកំពស់សេវាសាធារណៈនៅក្នុងវិស័យសង្គមកិច្ច ជាពិសេស វិស័យអប់រំ និងសុខាភិបាល
  - ការបន្តផ្តល់អាទិភាពដល់ការបង្កើន និង លើកកំពស់សកម្មភាពដែលបំរើអោយវិស័យសេដ្ឋកិច្ច ជាពិសេស វិស័យកសិកម្ម ធារាសាស្ត្រ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអភិវឌ្ឍន៍ជនបទ ។
- ធានាការបន្តអនុវត្តកម្មវិធីកែទម្រង់ និង អភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ កម្មវិធីកែទម្រង់ការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ កម្មវិធីកែទម្រង់កងទ័ព កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ កម្មវិធីអភិវឌ្ឍន៍ផ្នែកឯកជន និងការពង្រឹងអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាល ។

១១- ដើម្បីធានាអោយបាននូវការអនុវត្តទៅតាមគោលដៅខាងលើនេះ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដែលបានគូសបញ្ជាក់ខាងលើ ថវិកាឆ្នាំ ២០១០ ត្រូវគ្រោង និងរៀបចំឡើងលើមូលដ្ឋានយុទ្ធសាស្ត្រ និងវិធានការដូចខាងក្រោម ÷

- បន្តពង្រឹងការគ្រប់គ្រងចំណូល និងជំរុញការប្រមូលចំណូល ជាពិសេស ការអនុវត្តអោយបានសម្រេចទៅតាមផែនការសកម្មភាព និង គោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាសម្រេចអោយបាននូវកម្រិតចំណូលក្នុងស្រុកសរុបប្រមាណ ១២,៦% នៃផសស គឺមានកំណើន ០,៦% នៃផសស ធៀបនឹងឆ្នាំ ២០០៩ ដែលក្នុងនោះ ចំណូលសារពើពន្ធត្រូវសម្រេចអោយបាន ១០,៦% នៃផសស គឺមានកំណើន ០,៥% នៃផសស ធៀបនឹងឆ្នាំ ២០០៩ ចំណូលមិនមែនសារពើពន្ធត្រូវសម្រេចអោយបាន ១,៩% នៃផសស ប្រហាក់ប្រហែលនឹងឆ្នាំ ២០០៩ ។

- បន្តពង្រឹងការរៀបចំថវិកា អោយកាន់តែមានភាពច្បាស់លាស់ និងសុក្រឹតភាព តាមរយៈ ការបន្តជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំគោលនយោបាយចំណូល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមអោយបានច្បាស់លាស់ និងសុក្រឹត ការធ្វើសមាហរណកម្មថវិកា និងការបន្តកែលម្អការអនុវត្តថវិកាតាមកម្មវិធី ។

- បន្តពង្រឹងការគ្រប់គ្រងចំណាយ ជាពិសេស បន្តពង្រឹង និងជំរុញការកែលម្អការអនុវត្ត ថវិកាតាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងពាក់កណ្តាលឆ្នាំ ការបន្តពង្រឹងការអនុវត្តវិសហមជ្ឈការលទ្ធកម្មសាធារណៈ និងការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុងដើម្បីបន្តពង្រឹង ***ភាពជឿទុកចិត្តបាននៃថវិកា*** ដែលសម្រេចបាននៅក្នុង ដំណាក់កាលទី ១ ដែលនឹងនៅតែជាមូលដ្ឋានដ៏សំខាន់ និងចាំបាច់សម្រាប់ការឈានទៅដំណាក់កាលទី២ ***គឺការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ*** និង បណ្តាដំណាក់កាលបន្តបន្ទាប់ទៀត ។

- បន្តពង្រឹង និងបង្កើនការអនុវត្តប្លង់គណនេយ្យថ្មី និងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាថ្មី ប្រព័ន្ធកត់ត្រា និងរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុ អោយកាន់តែសុក្រឹត ព្រមទាំង ការត្រួតពិនិត្យផ្ទៃក្នុង និង ជាពិសេស ឈានទៅកំណត់ និងដាក់អោយអនុវត្តនូវចំណាត់ថ្នាក់មុខងារ អង្គភាពថវិកា បរិបថ និង នីតិវិធីអនុវត្តថវិកាថ្មី ដើម្បីឈានទៅអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រព័ន្ធព័ត៌មានវិទ្យា ដែលជាសកម្មភាពការងារដ៏ចំបងសម្រាប់សម្រេចជំហានទី ២ គឺ ***ការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ*** នៅក្នុងក្របខ័ណ្ឌនៃកម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

- បន្តការរឹតត្បិតចំណាយចរន្ត ជាពិសេស ការបន្តសន្សំសំចៃលើមុខសញ្ញាចំណាយ អគ្គិសនី ទូរស័ព្ទ ប្រេងឥន្ធនៈ ដើម្បីរក្សាចំណាយសរុបអោយស្ថិតនៅក្នុងកម្រិត ១៧,៧% នៃផសស គឺកើនឡើងប្រមាណ ០,១% នៃផសស ធៀបនឹងឆ្នាំ ២០០៩ ដែលក្នុងនោះ ចំណាយចរន្តនឹងត្រូវបានរក្សាអោយនៅត្រឹមប្រមាណ ១០,៦% និងចំណាយមូលធននឹងត្រូវបានរក្សានៅត្រឹមប្រមាណ ៧,១% នៃផសស ក្នុងទិសដៅរក្សាអតិរេកចរន្តក្នុងរង្វង់ ១,៩% នៃផសស និងឱនភាពថវិកាសរុប ក្នុងរង្វង់ ៥% នៃផសស ដោយមិនគិតហិរញ្ញប្បទានឥតសំណង និងប្រមាណ ៣% នៃផសស ដោយគិតទាំងហិរញ្ញប្បទានឥតសំណង ។

• បន្តផ្តល់អាទិភាព និងជំរុញការអនុវត្តថវិកាតាមកម្មវិធី និងការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដើម្បីបង្កើនប្រសិទ្ធភាពថវិកា និង ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ជាពិសេស បន្តពិនិត្យលទ្ធភាពដើម្បីពង្រីកការសាកល្បងការអនុវត្ត ថវិកាតាមកម្មវិធី តាមរយៈការបង្កើនទំហំថវិកាតាមកម្មវិធី និង ពង្រីកការអនុវត្តទៅក្រសួងផ្សេងទៀតក្រៅពីក្រសួង ៨ ដែលបាន និងកំពុងអនុវត្តនៅក្នុងឆ្នាំ ២០០៩ នេះ (ក្រសួងអប់រំយុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងយុត្តិធម៌ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកិច្ចការនារី និងក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ) ។

• បន្តផ្តល់អាទិភាពលើកិច្ចការវិនិយោគសាធារណៈ ជាពិសេស លើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមានផ្លូវ ស្ពាន ប្រព័ន្ធស្រោចស្រព និងការវិនិយោគលើការលើកកម្ពស់ផលិតភាពកសិកម្ម និង កសិ-ឧស្សាហកម្ម ។

## III. សេចក្តីណែនាំអំពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

១២- ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០០៩-២០១១ របស់ខ្លួន និង ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈខាងលើ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត នីមួយៗ ត្រូវត្រួតពិនិត្យឡើងវិញ និងវាយតំលៃលើការអនុវត្តកន្លងមក ដើម្បីកែសម្រួល និងរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១០-២០១២ ទៅតាមគំរូដូចបានភ្ជាប់មកជាមួយសារាចរណែនាំនេះ ។ គំរូផែនការយុទ្ធសាស្ត្រថវិកា ២០១០-២០១២ ដែលត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នេះរួមមាន ៥ ផ្នែកគឺៈ

***ផ្នែកទី ១ៈ មុខងារ និងភារកិច្ច*** គឺជាការបញ្ជាក់អំពីមុខងារ ភារកិច្ច និង ការទទួលខុសត្រូវរួមរបស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី ខេត្ត ដែលបានកំណត់ និងប្រគល់ដោយរាជរដ្ឋាភិបាល ។

***ផ្នែកទី ២ៈ ទិសដៅគោលនយោបាយ*** គឺជាទិសដៅគោលនយោបាយរយៈពេលមធ្យម (ពី ៣ ទៅ ៥ ឆ្នាំ) ដែលត្រូវបានកំណត់ដោយក្រសួង-ស្ថាប័ន ដើម្បីអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ដែលរាជរដ្ឋាភិបាលបានប្រគល់ជូន ជាពិសេស ដើម្បីរួមចំណែកអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** ដើម្បី កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ជីវភាពរបស់ប្រជាពលរដ្ឋ ។

***ផ្នែកទី ៣ៈ កម្មវិធី ឬ យុទ្ធសាស្ត្រអាទិភាព និង តំរូវការធនធាន*** គឺជាកម្មវិធី ឬយុទ្ធសាស្ត្រ អាទិភាពដែលកំណត់ដោយក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ដើម្បីអនុវត្ត និងសំរេច អោយបាននូវទិសដៅគោលនយោបាយរយៈពេលមធ្យមដែលបានកំណត់នៅក្នុងផ្នែកទី ២ ខាងលើ ។ ការកំណត់កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនេះ ត្រូវតែមានលក្ខណៈគ្រប់ជ្រុងជ្រោយ គឺរួមមានទាំង កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពសម្រាប់ថវិកាជាតិ និងថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ ។ កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ត្រូវគណនាតំរូវការធនធានអោយបានច្បាស់លាស់ទៅតាមឆ្នាំ ប្រភេទចំណាយ និងប្រភពធនធាន ដូចក្នុងតារាងទី ៣.១ និង៣.២ នៃគំរូផែនការយុទ្ធសាស្ត្រ ថវិកាដែលភ្ជាប់ជាមួយសារាចរណែនាំនេះ ។

***ផ្នែកទី ៤: ការកំណត់សូចនាករ និងគោលដៅសូចនាករ*** គឺជាការកំណត់សូចនាករ និង គោលដៅសម្រាប់វាស់លទ្ធផលសម្រេចបានពីការអនុវត្តកម្មវិធី ឬ យុទ្ធសាស្ត្រអាទិភាពនីមួយៗ ដែលក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត បានកំណត់ ដើម្បីសំរេចបាននូវគោលដៅនៃ ទិសដៅគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ដែលនឹងរួមចំណែកក្នុងការអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** របស់រាជរដ្ឋាភិបាល ។ សូចនាករនីមួយៗ ត្រូវមានការពន្យល់ពីមូលហេតុដែលត្រូវបានជ្រើសរើស បញ្ជាក់អំពីស្ថានភាពបច្ចុប្បន្ន កំណត់គោលដៅនៃលទ្ធផលក្នុងឆ្នាំនីមួយៗ និងកំណត់គោលដៅនៃលទ្ធផលចុងក្រោយ ដូចក្នុងតារាងទី ៤.១ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលបានភ្ជាប់មកជាមួយសារាចរណែនាំនេះ ។

***ផ្នែកទី ៤: ការគ្រោង និង ព្យាករណ៍ចំណូល*** គឺជាការគ្រោង និងព្យាករណ៍ចំណូលសម្រាប់ រយៈពេល ៣ ឆ្នាំ (២០១០-២០១២) របស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ដែលមាន ភារកិច្ចប្រមូលចំណូល ដោយផ្អែកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ខាងលើ ព្រមទាំងលទ្ធផល និង បទពិសោធន៍ក្នុងការអនុវត្តនៃបណ្តាឆ្នាំកន្លងមក រួមទាំងគោលនយោបាយ និងវិធានការថ្មី ដែលគ្រោងនឹងដាក់អោយអនុវត្ត ។ ការគ្រោង និងព្យាករណ៍ចំណូលនេះ ត្រូវគិតបញ្ចូលគ្រប់ប្រភេទនៃចំណូលទាំងអស់ រួមទាំងចំណូលដែលបានមកពីដៃគូអភិវឌ្ឍន៍សម្រាប់ អនុវត្តគំរោងនៅក្នុងក្រសួង-ស្ថាប័ន ផងដែរ ។

១៣- ទទួលបានសារាចរណែនាំនេះ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ទាំងអស់ ត្រូវអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ ។ ក្នុងករណី ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញ រាជធានី ខេត្ត មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាអោយបានទាន់ពេលវេលាតាមកាលកំណត់ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែឧសភា ឆ្នាំ ២០០៩*

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**__កន្លែងទទួល__**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

"***ដើម្បីជូនជ្រាប***"

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-រាជកិច្ច "ដើម្បីចុះផ្សាយ"

-គ្រប់ក្រសួង-ស្ថាប័ន

-គ្រប់អភិបាលរាជធានី-ខេត្ត

-គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត

"***ដើម្បីអនុវត្ត***"

-ឯកសារ-កាលប្បវត្តិ

(គម្រូប៉ែបបទសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកាដែលភ្ជាប់នឹងសារាចរ)

# ផែនការយុទ្ធសាស្ត្រថវិកា
# សំរាប់ឆ្នាំ ២០១០-២០១២

## របស់ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញ.................

### I. មុខងារ និងភារកិច្ច

ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញ........មានមុខងារ និង ភារកិច្ច......................................................... ។

### II. ទិសដៅគោលនយោបាយ

ដើម្បីរួមចំណែកអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង ជាពិសេសការបន្តជំរុញការអនុវត្ត **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** របស់រាជរដ្ឋាភិបាល ដើម្បី ***កំណើន ការងារ សមធម៌*** និង ***ប្រសិទ្ធភាព*** សំដៅសម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និង លើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញ........មានទិសដៅគោលនយោបាយដូចខាងក្រោម:

ទិសដៅគោលនយោបាយទី ១ :..........................................................................................

ទិសដៅគោលនយោបាយទី ២ :..........................................................................................

ទិសដៅគោលនយោបាយទី ៣ :..........................................................................................

ទិសដៅគោលនយោបាយទី ៤ :..........................................................................................

ទិសដៅគោលនយោបាយទី ៥ :..........................................................................................

### III. កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព និងតំរូវការធនធាន

ដើម្បីអនុវត្តទិសដៅគោលនយោបាយខាងលើអោយទទួលបានជោគជ័យ ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញ បានរៀបចំកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព និង បានកំណត់ពីតំរូវការធនធានដោយផ្អែកលើទិសដៅគោលនយោបាយ កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និង ផ្អែកលើបទពិសោធន៍អនុវត្តក្នុងឆ្នាំកន្លងមក រួមទាំងការសន្សំសំចៃដើម្បីប្រសិទ្ធភាពថវិកា ដែលមានដូចខាងក្រោម:

## តារាង ៣.១: កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព និង តំរូវការធនធានសម្រាប់ឆ្នាំ ២០១០-២០១២

ឯកតាគិតជាលានរៀល

| ទិសដៅគោលនយោបាយ | កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព | រយះពេលអនុវត្ត | តំរូវការធនធានសរុប | ធនធានបានអនុវត្តកន្លងមក | គ្រោងធនធានឆ្នាំ ២០១០ | ព្យាករណ៍តំរូវការធនធាន | | តំរូវការធនធានបន្ត |
|---|---|---|---|---|---|---|---|---|
| | | | | | | ឆ្នាំ ២០១១ | ឆ្នាំ ២០១២ | |
| ទិសដៅគ.ប ទី ១:...................... | ១.១:............................................................. | | | | | | | |
| | ១.២:............................................................. | | | | | | | |
| | ១.៣:............................................................. | | | | | | | |
| ទិសដៅគ.ប ទី ២:...................... | ២.១:............................................................. | | | | | | | |
| | ២.២:............................................................. | | | | | | | |
| | ២.៣:............................................................. | | | | | | | |
| ទិសដៅគ.ប ទី ៣:...................... | ៣.១:............................................................. | | | | | | | |
| | ៣.២:............................................................. | | | | | | | |
| | ៣.៣:............................................................. | | | | | | | |
| ............................................... | ................................................................... | | | | | | | |

## តារាង ៣.២: កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព និង តំរូវការធនធាន សម្រាប់ឆ្នាំ ២០១០-២០១២

ឯកតាគិតជាលានរៀល

| ទិសដៅគោលនយោបាយ កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព ប្រភេទចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០៩ | | | គ្រោងតំរូវការសេណទានសម្រាប់ ឆ្នាំ ២០១០ | | | ព្យាករណ៍តំរូវការសេណទានសម្រាប់ ឆ្នាំ ២០១១ | | | ព្យាករណ៍តំរូវការសេណទានសម្រាប់ ឆ្នាំ ២០១២ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ |
| ១. ទិសដៅគ.ប ទី ១<br>-សរុបចំណាយចរន្ត<br>បន្ទុកបុគ្គលិក<br>ក្រៅពីបន្ទុកបុគ្គលិក<br>-សរុបចំណាយមូលធន | | | | | | | | | | | | |
| ១.១: កម្មវិធី-យុទ្ធសាស្ត្រអាទិភាព ទី ១<br>-ចំណាយចរន្ត<br>បន្ទុកបុគ្គលិក<br>ក្រៅពីបន្ទុកបុគ្គលិក<br>-ចំណាយមូលធន | | | | | | | | | | | | |
| ១.២: កម្មវិធី-យុទ្ធសាស្ត្រអាទិភាព ទី ២<br>-ចំណាយចរន្ត<br>បន្ទុកបុគ្គលិក<br>ក្រៅពីបន្ទុកបុគ្គលិក<br>-ចំណាយមូលធន | | | | | | | | | | | | |
| ............................................................<br>.. | | | | | | | | | | | | |

## តារាង ៣.២: កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព និង តំរូវការធនធាន សម្រាប់ឆ្នាំ ២០១០-២០១២

ឯកតាគិតជាលានរៀល

| ទិសដៅគោលនយោបាយ កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព ប្រភេទចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០៩ | | | គ្រោងតំរូវការឥណទានសម្រាប់ ឆ្នាំ ២០១០ | | | ព្យាករណ៍តំរូវការឥណទានសម្រាប់ ឆ្នាំ ២០១១ | | | ព្យាករណ៍តំរូវការឥណទានសម្រាប់ ឆ្នាំ ២០១២ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ |
| ១. ទិសដៅគ.ប ទី ១ | | | | | | | | | | | | |
| -សរុបចំណាយចរន្ត | | | | | | | | | | | | |
| បន្ទុកបុគ្គលិក | | | | | | | | | | | | |
| ក្រៅពីបន្ទុកបុគ្គលិក | | | | | | | | | | | | |
| -សរុបចំណាយមូលធន | | | | | | | | | | | | |
| ១.១: កម្មវិធី-យុទ្ធសាស្ត្រអាទិភាព ទី ១ | | | | | | | | | | | | |
| -ចំណាយចរន្ត | | | | | | | | | | | | |
| បន្ទុកបុគ្គលិក | | | | | | | | | | | | |
| ក្រៅពីបន្ទុកបុគ្គលិក | | | | | | | | | | | | |
| -ចំណាយមូលធន | | | | | | | | | | | | |
| ១.២: កម្មវិធី-យុទ្ធសាស្ត្រអាទិភាព ទី ២ | | | | | | | | | | | | |
| -ចំណាយចរន្ត | | | | | | | | | | | | |
| បន្ទុកបុគ្គលិក | | | | | | | | | | | | |
| ក្រៅពីបន្ទុកបុគ្គលិក | | | | | | | | | | | | |
| -ចំណាយមូលធន | | | | | | | | | | | | |
| ..................................................... | | | | | | | | | | | | |
| .. | | | | | | | | | | | | |

## V. ការគ្រោង និងព្យាករណ៍ចំណូល

ដើម្បីរួមចំណែកដល់ការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការប្រមូលធនធានដើម្បីសំរេចឱ្យបាននូវក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលបានកំណត់ ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញ បានដាក់ចេញនូវយុទ្ធសាស្ត្រមួយចំនួនដើម្បីពង្រឹងការប្រមូលចំណូលដូចខាងក្រោម:

ក.....................................................

ខ.....................................................

គ.....................................................

តាមរយៈយុទ្ធសាស្ត្រនេះ ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញ បានគ្រោង និង ព្យាករណ៍ចំណូលដូចខាងក្រោម:

**តារាង ៥.១: ការគ្រោង និង ព្យាករណ៍ចំណូលសម្រាប់ឆ្នាំ ២០១០-២០១២**

ឯកតាគិតជាលានរៀល

| ប្រភេទចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០៩ | គ្រោង ឆ្នាំ ២០១០ | ព្យាករណ៍ ឆ្នាំ ២០១១ | ព្យាករណ៍ ឆ្នាំ ២០១២ |
|---|---|---|---|---|
| សរុបរួម | | | | |
| ១. ចំណូលពីប្រភពក្នុងស្រុក<br>-ចំណូលសារពើពន្ធ<br>-ចំណូលមិនមែនសារពើពន្ធ<br>-ចំណូលមូលធនក្នុងស្រុក | | | | |
| ២. ចំណូលពីប្រភពក្រៅស្រុក<br>គម្រោង/កម្មវិធី:............................<br>គម្រោង/កម្មវិធី:............................<br>គម្រោង/កម្មវិធី:............................ | | | | |